## យល់ពីវិក្កយប័ត្រទូរស័ព្ទរបស់អ្នក

វិក្កយប័ត្រទូរស័ព្ទ មាននូវព័ត៌មានជាច្រើន ហើយអាច-មានការពិបាកយល់ ។ មិនថាសេវា-ទូរស័ព្ទប្រភេទណាដែលអ្នកមាននោះឡើយ សូមចងចាំថា :

- អ្នកមានសិទ្ធិយល់ពីវិក្កយប័ត្រទូរស័ព្ទរបស់អ្នក។
- ពិនិត្យមើលវិក្កយប័ត្ររបស់អ្នកជារៀងរាល់ខែ ហើយប្រសិនបើមានអ្វីមួយនៅលើវាដែលអ្នកមិនយល់ ឬមិនបានស្នើសុំ សូមទូរស័ព្ទទៅក្រុមហ៊ុនទូរស័ព្ទភ្លាម និងស្នើសុំការពន្យល់។



មុនពេលអ្នកទូរស័ព្ទហៅ សូមអានខិតប័ណ្ណនេះ។ វាប្រហែលជាមានចម្លើយដែលអ្នកត្រូវការ។

**Cal Phone Info**
California Public Utilities Commission
Telecommunications Education for Consumers

ប្រសិនបើលោកអ្នកត្រូវការជំនួយសម្រ-
ាប់ជម្លោះស្តីអំពីសេវាកម្ម ឬ
វិក្កយប័ត្រទូរគមនាគមន៍របស់លោកអ្នក ដំបូង-
សូមទំនាក់ទំនងទៅកាន់
ក្រុមហ៊ុនទូរស័ព្ទរបស់លោកអ្នក។ ប្រសិនបើប-
ញ្ហារបស់អ្នកមិនត្រូវបានដោះស្រាយ អ្នកអាច-
ដាក់បណ្តឹងតាមអ៊ិនធ័រណេតតាមរយៈ:
www.calphoneinfo.com
ឬទូរស័ព្ទមកខ្សែទូរស័ព្ទបន្ទាន់ ជ្យនសុមរេ ។ថ-
ថាំរស ពរានចហ ានដ្ស តិលិតយ ធរាុជ ះ្យតលិនរេ
តាមរយៈ: 1(800) 649-7570

CPUC

Understanding Your Phone Bill - May 2012—Khmer

# យល់ពីវិក្កយប័ត្រទូរស័ព្ទរបស់អ្នក

CALIFORNIA
PUBLIC
UTILITIES
COMMISSION



# យល់ពីវិក្កយប័ត្រទូរស័ព្ទរបស់អ្នក



## តើមានអ្វីខ្លះនៅលើវិក្កយប័ត្រទូរស័ព្ទរបស់អ្នក

- សេចក្ដីសង្ខេប : ទឹកប្រាក់ និងការបង់ថ្លៃវិក្កយប័ត្រខែមុន ទឹកប្រាក់ជំពាក់នាពេលបច្ចុប្បន្ន និងថ្ងៃផុតកំណត់បង់ប្រាក់របស់អ្នក។
- ព័ត៌មានក្រុមហ៊ុន : របៀបដែលអ្នកអាចទាក់ទងក្រុមហ៊ុនទូរស័ព្ទ ប្រសិនបើអ្នកមានចម្ងល់អំពីវិក្កយប័ត្ររបស់អ្នក ឬសេវាផ្សេងៗ។
- ព័ត៌មាន CPUC និង FCC : របៀបទាក់ទងភ្នាក់ងារទាំងនេះ ប្រសិនបើអ្នកត្រូវការជំនួយដោះស្រាយជម្លោះ។
- គម្រោង និងសេវា : នេះពណ៌នាពីសេវាទូរស័ព្ទរបស់អ្នក និងថ្លៃរបស់ពួកវា។
- ប័ណ្ណបង់ប្រាក់ : ផ្ញើរប័ណ្ណនេះជាមួយមូលប្បទានបត្ររបស់អ្នក ប្រសិនបើអ្នកនឹងផ្ញើរការបង់ប្រាក់របស់អ្នកតាមសំបុត្រ។
- ថ្លៃពីក្រុមហ៊ុនផ្សេងទៀត : ប្រសិនបើក្រុមហ៊ុនមួយផ្សេងទៀតចេញវិក្កយប័ត្រឱ្យអ្នកសំរាប់ការហៅទូរស័ព្ទរយៈចម្ងាយឆ្ងាយ ឬសេវាផ្សេងទៀត ថ្លៃរបស់ពួកវា និងរបៀបទាក់ទងក្រុមហ៊ុននោះ នឹងបង្ហាញនៅក្នុងផ្នែកមួយផ្សេងទៀត។

## ថ្លៃបន្ថែម

វិក្កយប័ត្ររបស់អ្នក នឹងបង្ហាញថ្លៃបន្ថែមដូចជា :

- ថ្លៃតម្លើង : នេះជាថ្លៃតែម្ដងគត់សំរាប់ការចាប់ផ្ដើម ឬការប្ដូរសេវា។
- ថ្លៃ ពន្ធ និងថ្លៃសេ : រាល់ក្រុមហ៊ុនទូរស័ព្ទទាំងអស់ ប្រមូលយកថ្លៃទាំងនេះ។ ពួកវាត្រូវបានតម្រូវដោយរដ្ឋាភិបាល។
- ជំនួយផ្ដល់បញ្ជីរាយនាមឈ្មោះ និងលេខទូរស័ព្ទ : ជាធម្មតា ក្រុមហ៊ុនទូរស័ព្ទយកថ្លៃសំរាប់ការទទួលបានលេខទូរស័ព្ទពីជំនួយផ្ដល់បញ្ជីរាយឈ្មោះ និងលេខទូរស័ព្ទ - 411 ។
- ថ្លៃកាតទូរស័ព្ទហៅចេញ : ទាំងនេះគឺជាថ្លៃសំរាប់ការហៅចេញដែលអ្នកបានធ្វើឡើងទូរស័ព្ទមួយផ្សេងទៀត និងត្រូវបានចេញវិក្កយប័ត្រដោយប្រើប្រាស់ការទូរស័ព្ទហៅចេញ ដែលក្រុមហ៊ុនទូរស័ព្ទបានចេញឱ្យអ្នក។ ការហៅទូរស័ព្ទ អាចថ្លៃច្រើនជាងការហៅដោយផ្ទាល់ពីទូរស័ព្ទផ្ទាល់ខ្លួនរបស់អ្នក។
- ថ្លៃនាទីបន្ថែម : ប្រសិនបើអ្នកបានកំណត់សេវានៅលើទូរស័ព្ទរបស់អ្នក វិក្កយប័ត្រ នឹងបង្ហាញពីថ្លៃណាមួយសំរាប់ការប្រើលើសការអនុញ្ញាតផ្ដល់ជូនរបស់អ្នក។

## សេវាសំខាន់ៗប្រសើរបំផុត

ជាញឹកញាប់ ក្រុមហ៊ុនទូរស័ព្ទផ្ដល់ជូនសំណើដូចជា :

- ជាកញ្ចប់ : ក្រុមហ៊ុនមួយចំនួនលក់ជូននូវសេវាជាច្រើនដូចជា ទូរស័ព្ទ ខ្សែកាប និងអ៊ិនធ័រណិតជាកញ្ចប់មួយ។ វាអាចជាដំណោះស្រាយល្អមួយ ប្រសិនបើអ្នកចង់បានសេវាទាំងអស់។ ប្រសិនបើមិនទេ អ្នកយកល្អអាចទិញផ្ដាច់សេវាតិចជាងនេះនៅថ្លៃធម្មតាបាន។
- ជម្រើសសេវាមូលដ្ឋាន : ជាទូទៅ ក្រុមហ៊ុនទូរស័ព្ទលើតុក្នុងតំបន់ផ្ដល់ជូនជម្រើសពីរ :
    - a. លេខហៅចេញដោយឥតគិតថ្លៃមិនកំណត់នៅក្នុងតំបន់ សំរាប់អត្រាប្រចាំខែថេរមួយ។
    - b. ហៅចេញដោយឥតគិតថ្លៃមានកំណត់នៅក្នុងតំបន់នៅថ្លៃទាប ហើយអ្នកនឹងត្រូវបានចេញវិក្កយប័ត្រឱ្យបន្ថែម ប្រសិនបើអ្នកប្រើលើសកំណត់។ សេវានេះសន្សំប្រាក់ ប្រសិនបើអ្នកមិនធ្វើការហៅចេញច្រើនរៀងរាល់ខែ។
- ក្រុមហ៊ុនសេវាឥតខ្សែជាច្រើន ផ្ដល់ជូនសេវាដែលអ្នកបង់ប្រាក់ជាមុន ហើយនៅពេលនាទីរបស់អ្នកត្រូវបានប្រើប្រាស់អស់ អ្នកត្រូវទិញបន្ថែម។ ជាមួយនឹងគម្រោងទាំងនេះ នោះនឹងមិនមានវិក្កយប័ត្រប្រចាំខែទេ ឬវិក្កយប័ត្ររបស់អ្នកអាចនឹងកាន់តែមានភាពងាយស្រួល។







## ការបង់វិក្កយប័ត្ររបស់អ្នក

សូមផ្ញើរការបង់ប្រាក់របស់អ្នកប៉ុន្មានថ្ងៃមុនថ្ងៃដល់កំណត់ ដើម្បីចៀសវាងការបង់ប្រាក់ថ្លៃយឺតពេល ឬការកាត់ផ្ដាច់សេវា។ ប្រសិនបើអ្នកមិនអាចបង់ថ្លៃវិក្កយប័ត្រមុនថ្ងៃដល់កំណត់ នោះដើម្បីរក្សាឱ្យសេវារបស់អ្នកបន្តទៀត អ្នកត្រូវទូរស័ព្ទទៅក្រុមហ៊ុនទូរស័ព្ទរបស់អ្នក និងស្នើសុំថាតើអ្នកអាចបង់នៅថ្ងៃក្រោយ ឬបង់ប្រាក់មួយផ្នែកបានដែរឬអត់។

## ជម្លោះ

ប្រសិនបើអ្នកកំពុងមានជម្លោះនឹងថ្លៃទាំងឡាយ អ្នកត្រូវតែឱ្យក្រុមហ៊ុនទូរស័ព្ទរបស់អ្នកដឹង ឆាប់តាមដែលអាច។ សូមរក្សាកំណត់ត្រាពីពេលដែលអ្នកបានហៅចេញ មនុស្សដែលអ្នកបាននិយាយជាមួយ និងអ្វីដែលអ្នកបាននិយាយ។ ប្រសិនបើក្រុមហ៊ុននឹងមិនកែតម្រូវវិក្កយប័ត្ររបស់អ្នក អ្នកអាចដាក់បណ្ដឹងទៅកាន់គណៈកម្មការសេវាប្រើប្រាស់មូលដ្ឋានសាធារណៈរដ្ឋកាលីហ្វ័រញ៉ា។ សូមមើលខាងក្រោយខិតប័ណ្ណនេះ សំរាប់លំអិតពីទំនាក់ទំនង។